ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៩២៧ / ១៧-១០-២០១១

**សាលដីកា**

លេខ ០៩ "ក្រ.III.ច" / ២៩-០១-២០១៣

**តាមនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍ ភ្នំពេញ**

បង្កើតតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៦ក្រ ចុះថ្ងៃទី ០៨-០២-១៩៩៣ បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នៅថ្ងៃទី ១៧-០១-២០១៣ ដោយមានសមាសភាពដូចតទៅ:

សមាសភាពក្រុមប្រឹក្សាជំនុំជំរះ

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

តំណាងមហាអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញា

ក្រឡាបញ្ជី

លោក [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៩២៧ ចុះថ្ងៃទី ១៧-១០-២០១១ ដោយមានៈ

១-ជនជាប់ចោទជនជាប់ចោទឈ្មោះ [redacted] ឌុល ភេទប្រុស អាយុ២៩ឆ្នាំ ជាតិឥស្លាម មុខរបរ កម្មករ កើតនៅភូមិត្រពាំង ឃុំក្បាលកប្បាល ស្រុកកំពត ខេត្តកោះកុង មានទីលំនៅសព្វ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មាន កូន០៩នាក់ ទោសពីមុនគ្មាន ។ (ប្តឹងឧទ្ធរណ៍)

-មានមេធាវីការពារសិទ្ធិលោកស្រី [redacted] ភាសីតត្ត ។ ៤

៣៨

ត្រូវជាប់ចោទពីបទ ៖ ឃាតកម្មគិតទុកមុន ប្រព្រឹត្តនៅភូមិ០១ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង កាលពីថ្ងៃទី ២០.១១.២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទំរង់ទោសនៃបទឧក្រិដ្ឋ ។

**២-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted] ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ មានទីលំនៅ ភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ។

## ឯរឿងហេតុមានដូចតទៅ

កាលពីថ្ងៃទី ២០.១១.២០១១ វេលាម៉ោង១២.២០ នាទី រំលងអាធ្រាត ឈ្មោះ [redacted] ឌុល បានលួចចូលសំងំក្នុងផ្ទះឈ្មោះ [redacted] ហួត ហៅ ស្រីនាង ស្ថិតនៅភូមិ០១ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ដោយឈ្មោះ [redacted] ហួន ភ្លេចបិទទ្វារ ហើយទៅលេងបៀរនៅតូបមុខផ្ទះ ។ ពេលឈប់លេងបៀរឈ្មោះ [redacted] ហួន បានត្រឡប់ទៅផ្ទះដេក ទើបឈ្មោះ [redacted] ឌុល ធ្វើសកម្មភាពចាប់រំលោភឈ្មោះ [redacted] ហួន រើបំរាស់និងស្រែកទ្រហ៊ូកជិតខានជួយទើបឈ្មោះ [redacted] ឌុល យកកាំបិតចុងស្រួចចាក់ត្រង់កបណ្តាលឲ្យស្លាប់តែម្តង ។ ពេលធ្វើសកម្មជាពរំលោភ និងសំលាប់រួចហើយ ជនល្មើសក៏ចុះតាមបង្អួចជាន់របងបណ្តាលឲ្យរបួសត្រង់បាតជើង ។

**-បានឃើញ**សាលក្រមព្រហ្មទណ្ឌលេខ ១៣៨ "ង" ចុះថ្ងៃទី ១៩.០៩.២០១១ របស់សាលាដំបូងខេត្តកោះកុង ដែលបានសេចក្តីសំរេចដូចតទៅ ៖

១-ផ្តន្ទាទោសឈ្មោះ [redacted] ឌុល ភេទប្រុស អាយុ២៩ឆ្នាំ ជនជាតិឥស្លាម ដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ (ដប់ប្រាំឆ្នាំ) ពីបទ ឃាតកម្មគិតទុកជាមុន នៅភូមិ
០១ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង កាលពីថ្ងៃទី ២០.១១.០៩ តាមបញ្ញត្តិមាត្រា ៣ ច្បាប់ស្តីពីស្ថានទំនង់ទោសនៃបទឧក្រិដ្ឋ ។

២-វត្ថុតាងមាន ៖

-ដំបងឈើស្មាច់ប្រវែង ០១ ម៉ែត្របីតឹក ចំនួន ០១ ដើម

-កូនកាំបិតដងខ្មៅប្រវែង ១៧ សង់ទីម៉ែត្រ ចំនួន ០២ ដើម

-បំណែកកញ្ចក់ចំនួន ០១ បន្ទះ (មួយបន្ទះ)

-ទ្រនាប់ជើងកូនក្មេងពណ៌ត្នោតចំនួន ០១គូរ

សំរេចរឹបអូស និងបំផ្លាញចោល ។

៣-សាលក្រមនេះជំនុំជំរះជាសាធារណៈ និងប្រកាសជាតកាធារណៈនៅថ្ងៃទី ១៩.០៩.២០១១ ចំពោះមុខជនជាប់ចោទ , មេធាវី កំបាំងមុខដើមរដ្ឋប្បវេណី បើកសិទ្ធិប្តឹងទាស់ រឺ ប្តឹងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ ។



Scanned with CamScanner

បានឃើញពាក្យបណ្ដឹងឧទ្ធរណ៍លេខ ២៨ ចុះថ្ងៃទី ២២-០៩-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] ឌុល ប្ដឹងសាលក្រមព្រហ្មទណ្ឌលេខ ១៣៨ "ង" ចុះថ្ងៃទី ១៩-០៩-២០១១ របស់សាលាដំបូងខេត្តកោះកុង ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

បានឃើញរបាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ។

បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

**នាពេលសវនាការ**

**ប្រធានក្រុមប្រឹក្សាជំនុំជំរះ បានអានរបាយការណ៍សង្ខេបនៃរឿង**

-ជនជាប់ចោទឈ្មោះ [redacted] ឌុល (អវត្តមាន)

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] (អវត្តមាន)

-ក្រឡាបញ្ជីបានអានចម្លើយរបស់ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សី ។

**តំណាងមហាអយ្យការធ្វើសេចក្ដីសន្និដ្ឋាន**

ជនជាប់ចោទធ្លាប់បានទៅដេកនៅផ្ទះជនរងគ្រោះ មានការស៊ើបសង្កាត់ទៅនឹងចម្លើយសាក្សីដែលបានឃើញជនជាប់ចោទតែងតែចេញចូលផ្ទះជនរងគ្រោះ នៅថ្ងៃកើតហេតុ ជនជាប់ចោទមានរបួសជើង និងដៃ មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ សុំតម្កល់សាលក្រម ទុកជាបានការ។

**មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋាន**

កូនក្ដីខ្លួនឈ្មោះ [redacted] ឌុល មិនបានសំលាប់ជនរងគ្រោះទេ គ្មានសាក្សីណាបានឃើញ និងផ្ទាល់ភ្នែកទេ ក្នុងកំណត់ហេតុកូនក្ដីខ្លួនបដិសេធរហូត សុំលុបចោលសាលក្រមរបស់សាលាដំបូង សុំលើកលែងការចោទប្រកាន់ ។

**តុលាការថយទៅពិភាក្សា**

ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ។

ក្រោយពីបានស្ដាប់តំណាងមហាអយ្យការធ្វើសន្និដ្ឋាន។

ក្រោយពីបានស្ដាប់ការសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ។

ក្រោយពីបានពិភាក្សាត្រឹមត្រូវហើយ។

**<u>សាលាឧទ្ធរណ៍</u>**

**<u>យល់ឃើញថា:</u>**

១-បណ្ដឹងឧទ្ធរណ៍លេខ ២៨ ចុះថ្ងៃទី ២២.០៩.១១ របស់ជនជាប់ចោទឈ្មោះ [redacted] ឌុល ប្ដឹងនិងសាលក្រមព្រហ្មទណ្ឌលេខ ១៣៨ "ង" ចុះថ្ងៃទី ១៩.០៩.២០១១ របស់សាលាដំបូងខេត្តកោះកុង ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចទទួលជំនុំជំរះបាន តាមមាត្រា ៣៨២



Scanned with CamScanner

នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ទោះបីជនជាប់ចោទឆ្លើយបដិសេធថាពុំបានប្រព្រឹត្តទៅលើជនរងគ្រោះ ក៏ជនជាប់ចោទពុំមានភស្តុតាង រឺ សាក្សីណាមួយ មកបញ្ជាក់ថាខ្លួនពុំបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់នេះដែរ ដូចនេះសាលាឧទ្ធរណ៍ពុំមានហេតុផល មកធ្វើការ ពិចារណាដែរ ។

៣-មានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទពីបទឃាតកម្មគិតទុកមុន ប្រព្រឹត្តនៅភូមិ០១ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង កាលពីថ្ងៃទី ២០.១១.២០១១ តាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ។

៤-សាលក្រមព្រហ្មទណ្ឌលេខ ១៣៨ "ង" ចុះថ្ងៃទី ១៩.០៩.២០១១ របស់សាលាដំបូងខេត្តកោះកុង បានសម្រេចសេចក្តីមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់ហើយ គប្បីតម្កល់ទុកជាបានការ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ២៨ ចុះថ្ងៃទី ២២.០៩.២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] ឌុល ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់និងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៣៨ "ង" ចុះថ្ងៃទី ១៩.០៩.២០១១ របស់សាលាដំបូងខេត្តកោះកុង ទុកជាបានការដដែល ។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់ ។

៤-សាលដីការនេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី ១៧.០១.២០១៣ និងប្រកាសជាសាធារណៈថ្ងៃទី ២៩.០១.២០១៣ កំបាំងមុខជនជាប់ចោទ និង ចំពោះមុខមេធាវីការពារជនជាប់ចោទ បើកផ្លូវប្តឹងតវ៉ា ក្នុងកំណត់ច្បាប់ ។

**សេចក្តីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះ ឱ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ** |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] . [redacted] | ហត្ថលេខា: [redacted] |

បានចំលងត្រឹមត្រូវតាមច្បាប់ដើម
សាលាឧទ្ធរណ៍ ថ្ងៃទី... ខែ...៦.....ឆ្នាំ២០១៤
ក្រឡាបញ្ជី
[redacted]

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]



Scanned with CamScanner